# កិច្ចប្រជុំសមាជិកប្រចាំពីរខែ -អង្គការ គ.ស.ក

**៥ មេសា ២០១៨ វេលាម៉ោង ៨:០០-១២:០០ព្រឹក**

*អាគារ ដាកូនៀរ សិនធីរ* (KSSA/ICF *ជិតសារៈមន្ទីរឧក្រិដ្ឋកម្មទួលស្លែង*)

## សេចក្ដីផ្ដើម

កិច្ចប្រជុំសមាជិកប្រចាំខែលើកទី ២៥១ នឹងប្រព្រឹត្តិទៅនៅ អាគារ ដាកូនៀរ *(KSSA/ICF ផ្ទះលេខ ១៩-២១ ផ្លូវ ៣៣០ រាជធានីភ្នំពេញ)* នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨។ យោងតាមលក្ខន្តិកៈរបស់អង្គការ គ.ស.ក កិច្ចប្រជុំនេះរៀបចំឡើង ដែលមានការចូលរួមពីអ្នកតំណាងប្រចាំប្រទេស/នាយកប្រតិបត្តិ និងអ្នកដឹកនាំជាន់ខ្ពស់/អ្នកគ្រប់គ្រងរបស់សមាជិក អង្គការ គ.ស.ក ការចូលរួមនេះនឹងនាំយកការព្រួយបារម្ភលើបញ្ហាប្រឈមនានា ជុំវិញការអភិវឌ្ឍ និងកំណត់អាទិភាពលើបញ្ហាដែលត្រូវដោះស្រាយដោយភាគីពាក់ព័ន្ធ។

**កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីៈ**

១. ស្វាគមន៍សមាជិកថ្មី និងការចែករំលែកវិធីសាស្ត្រអភិវឌ្ឍន៍
២. ចែករំលែក និងធ្វើបច្ចុប្បន្នភាពស្ថានភាពផ្លូវច្បាប់ គោលការណ៍អភិវឌ្ឍន៍ និងរបៀបវារៈផ្សេងៗក្នុងភាពជាដៃគូ ដែលពាក់ព័ន្ធនឹងសមាជិកអង្គការ គ.ស.ក និងដៃគូ/អង្គការសង្គមស៊ីវិលនានា
៣. ចែករំលែក និងពិភាក្សាអំពី សេចក្តីថ្លែងការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំ និងសកម្មភាពដែលបានស្នើ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលសំខាន់ៗមួយចំនួនដែលបានលើកឡើង។

## របៀបវារៈ

| ម៉ោង | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| ៨:០០-៨:៣០ | ចុះឈ្មោះ និង សំណេះសំណាលរវាងសមាជិក | អង្គការ គ.ស.ក និងសមាជិក |
| ៨:៣០ | គោរពភ្លេងជាតិ | អ្នកកាន់កម្មវិធី<br>**អ្នកស្រី ចាន់ សុម៉ាលី**<br>អ្នកជំនាញផ្នែកសមាជិកភាព<br>អង្គការ គ.ស.ក |
| ៨:៣០-៨:៤៥ | កិច្ចស្វាគមន៍ និង មតិបើកកម្មវិធី | **លោក សឿង សារឿន**<br>នាយកប្រតិបត្តិអង្គការគ.ស.ក |
| ៨:៤៥-៩:០៥ | **វគ្គទី១ៈ ការចែករំលែករបស់សមាជិក គ.ស.ក**<br>បទបង្ហាញរបស់សមាជិកថ្មី និងវិធីសាស្ត្រសម្រាប់អភិវឌ្ឍន៍<br><br>**សំណួរ & ចម្លើយ** | **លោក កើត សាមុត**<br><br>តំណាងអង្គការ CCRC |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability GPP Symbol of Trust

| | | |
|---|---|---|
| ៩:០៥-៩:៤៥ | **វគ្គទី២៖ ការចែករំលែក និងការធ្វើបច្ចុប្បន្នភាពពីស្ថានភាពច្បាប់/គោលការណ៍អភិវឌ្ឍន៍ និងរបៀបវារៈក្នុងភាពជាដៃគូ**<br>• បច្ចុប្បន្នភាពលើច្បាប់ LANGO (ការដាក់ស្នើរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុ)<br>• ធ្វើបច្ចុប្បន្នភាពលើការអនុវត្តន៍ និងកាតព្វកិច្ចពាក់ព័ន្ធច្បាប់ការងារ (របបសន្តិសុខសង្គម និងថែទាំសុខភាព)<br>• ចែករំលែកលើខ្ទង់ថវិកាជាតិ ២០១៨<br>• ចែករំលែកស្តីពីច្បាប់ស្តីពី សិទ្ធិទទួលបានព័ត៌មាន<br>• ចែករំលែកអំពីភាពជាដៃគូសង្គមស៊ីវិលដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍ (CPDE) និងខួបលើកទី 8 នៃកិច្ចព្រមព្រៀងសម្រាប់ប្រសិទ្ធភាពនៃការអភិវឌ្ឍន៍របស់អង្គការសង្គមស៊ីវិលនៅខេត្តសៀមរាប និងខួបលើកទី 3 នៃSDGs ។<br>**សំនួរ & ចម្លើយ** | **លោក យឿង សុធារ៉ា**<br>អ្នកជំនាញផ្នែកច្បាប់<br>អង្គការ គ.ស.ក |
| ៩:៤៥-១០:០០ | សម្រាកអាហារសម្រន់ | សមាជិកទាំងអស់ |
| ១០:០០-១១:៣០ | **វគ្គទី៣៖ ការចែករំលែក និងពិភាក្សាសេចក្តីថ្លែងការណ៍លទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំ(AGM) និងសកម្មភាពបន្ទាប់ ដែលពាក់ព័ន្ធនឹងសំណើផ្សេងៗ៖**<br>• លទ្ធផលនៃកិច្ចប្រជុំក្រុមការងារ និងធ្វើបច្ចុប្បន្នភាពពីលទ្ធផលទស្សនៈកិច្ចអង្គការបណ្តាញខេត្ត<br>**ពិភាក្សាក្រុមនូវសកម្មភាពដែលបានស្នើឡើង សំខាន់ៗពី AGM និងសកម្មភាពអនុវត្តបន្ត៖**<br>១. សន្និបាទសម្រាប់អង្គការសង្គមស៊ីវិល<br>២. ការពង្រីកសមាជិកភាព<br>៣. ការពិភាក្សារវាងសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍<br>**បទបង្ហាញមកកាន់ក្រុមធំពីក្រុមនីមួយៗ** | **អ្នកស្រីបណ្ឌិត អែល សុធារី**<br>ប្រធានកម្មវិធី អង្គការគ.ស.ក |
| ១០:៣០-១១:៤៥ | ស្ទង់មតិពីការអនុលោមច្បាប់ និងការវាយតម្លៃកិច្ចប្រជុំប្រចាំខែ | អ្នកកាន់កម្មវិធី |
| ១០:៤៥-១២:០០ | សរុបនិងមតិបិទ | **លោក សឿង សារឿន**<br>នាយកប្រតិបត្តិ អង្គការគ.ស.ក |

សម្គាល់៖ អង្គការ គ.ស.ក សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូររបៀបវារៈក្នុងករណីចាំបាច់អាស្រ័យលើពេលវេលា នឹងវាគ្មិន។ ឯកសារ រូបថត និងសកម្មភាពសំខាន់ៗក្នុងកិច្ចប្រជុំនេះ នឹងមានផ្សព្វផ្សាយនៅក្នុងគេហទំព័រ អង្គការ គ.ស.ក និងប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់ប្រើជាសាធារណៈ។សូមទាញយកបណ្ណាសារក្នុងតំណភ្ជាប់៖ http://www.ccc-cambodia.org/en/resources/event-archives www.facebook.com/CCCsince1990 www.youtube.com/CCCambodia



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia